**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសំរាប់គំរោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន**

**ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៤**

- សូមគោរព **លោកស្រី អ៊ីជិហារ៉ា គាហ្សឺកុ** តំណាងប្រចាំប្រទេសអង្គការមូលនិធិជប៉ុន PHJ
- សូមគោរព ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីរៀបចំពិធីចុះហត្ថលេខាផ្តល់ជំនួយឧបត្ថម្ភសំរាប់គំរោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន “គំរោងពង្រឹងប្រពន្ធ័ថែទាំសុខភាពបឋមមាតា និងទារកនៅខេត្តកំពង់ចាម” ។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីកែលំអធ្វើអោយប្រសើរឡើងនូវស្ថានភាពសុខភាពមាតា និងទារក ដោយសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សក្នុងវិស័យសុខភាពមាតា និងទារក ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសជិតខាងដែលនៅជុំវិញនេះ អត្រាមរណៈភាពនៅប្រទេសកម្ពុជានៅតែមានកំរិតខ្ពស់ ។ នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ការកែលំអធ្វើអោយប្រសើរឡើងនូវសុខភាពមាតា និងទារក ក៏ត្រូវបានចាត់ទុកថាជាវិស័យដ៏សំខាន់មួយផងដែរ ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងជួយដល់កិច្ចកិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍន៍របស់ប្រជាជនកម្ពុជា ដោយផ្តល់ជំនួយឧបត្ថម្ភលើគំរោងជាច្រើនបែប មានដូចជាការកែលំអសំណង់អាគារសុខាភិបាល និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងវិស័យសុខភាពមាតា និងទារក ។ ជាពិសេស នៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ដែលត្រូវបានសាងសង់ឡើងដោយជំនួយរបស់ជប៉ុននៅក្នុងឆ្នាំ ១៩៩៧ ក្នុងនោះរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមបញ្ជូនអ្នកជំនាញការមក និងជួយអភិវឌ្ឍន៍ធនធានមនុស្ស ។ យើងក៏បានជួយផងដែរដល់ការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងខេត្តកំពង់ចាម ក្រោមគំរោងជំនួយសាងសង់អាគារបណ្តុះបណ្តាលថ្មីមួយនៅក្នុងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ។

អង្គការមូលនិធិជប៉ុន PHJ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ ២០០៤ មកដើម្បីកែលំអស្ថានភាពសុខភាពមាតា និងទារកនៅក្នុងខេត្តកំពង់ធំ ។ ក្នុងរយៈពេលជិតប្រាំឆ្នាំ អង្គការមូលនិធិជប៉ុន

PHJ បានជួយដល់ការកែលំអសុខភាពមាតា និងទារកនៅភាគខាងត្បូងនៃខេត្តកំពង់ធំ តាមរយៈជំនួយឧបត្ថម្ភរបស់ រដ្ឋាភិបាលជប៉ុនផ្តល់ជូនសំរាប់គំរោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ។ ជាមួយនឹងជំនួយនេះ ចំនួនស្ត្រីដែល មកសំរាលបុត្រ និងស្ត្រីដែលមកធ្វើការត្រួតពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពមានការកើនឡើង ហើយការយល់ដឹងរបស់ប្រជាជនអំពីបញ្ហាសុខភាពមាតា និងទារកក៏កាន់តែមានភាពប្រសើរឡើង ។

អង្គការមូលនិធិជប៉ុន PHJ បានចាប់ផ្តើមមានគំរោងពង្រឹងមុខងារស្រុកប្រតិបត្តិ សំណង់អាគារសុខាភិបាល និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងតំបន់ប្រតិបត្តិថ្មីៗ នៅស្រុកប្រតិបត្តិស្ទឹងត្រង់ ក្នុងខេត្តកំពង់ចាម ។ គំរោងនេះ សង្ឃឹមថានឹងជួយពង្រឹងការយល់ដឹងរបស់ប្រជាជនអំពីបញ្ហាសុខភាពមាតា និងទារក និងបង្កើតឡើងនូវរបៀបរបបនៃការរស់នៅប្រកបដោយអនាម័យ និងមានសុខភាពល្អដល់ប្រជាជននៅក្នុងតំបន់ប្រមាណ ៣២.០០០ នាក់ ។

ចុងបញ្ចប់ គំរោងនេះត្រូវនឹងគោលការណ៍ដើម្បីគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលអនុវត្តនូវគំរោងនានាដើម្បីជួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅថ្នាក់មូលដ្ឋាន ។ ខ្ញុំសូមសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ចំពោះលោក-អ្នកទាំងអស់ដែលបានចូលរួមនៅក្នុងគំរោងសុខភាពមាតា និងទារកនៅកម្ពុជា ។ ខ្ញុំសង្ឃឹមដោយស្មោះសរថា គំរោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចស្រាប់មកហើយរវាងប្រជាជនជប៉ុននិងប្រជាជនកម្ពុជា ហើយនឹងត្រូវបានអនុវត្តដោយរលូននិងថែរក្សាបានយ៉ាងល្អ ដោយហេតុនោះប្រជាជននៅមូលដ្ឋាននឹងអាចទទួលបាននូវផលប្រយោជន៍អំពីគំរោង។

សូមអរគុណ ។